# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

## Khmer Kampuchea Krom Women Organization Bulletin

*ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ៣៣ ពីថ្ងៃទី០១-១៥ ខែធ្នូ ឆ្នាំ២០០៩*

# ខ្មែរកម្ពុជាក្រោម
# អបអរសាទរខួបលើកទី៦១ ទិវាសិទ្ធិមនុស្សអន្តរជាតិ

ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ ឆ្នាំ២០០៩ របស់បងប្អូនខ្មែរកម្ពុជាក្រោមមានឧបសគ្គខ្លះ។ដូចជាអាជ្ញាធរសាលារាជធានីភ្នំពេញ មានការយឺតយ៉ាវនៃការអនុញ្ញាតច្បាប់ គឺនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ វេលាម៉ោង៤,០០នាទីរសៀល ទើបបានលិខិតអនុញ្ញាតពីសាលារាជធានីភ្នំពេញ ពេលនោះគណៈកម្មការរៀបចំបុណ្យ បានទំនាក់ទំនងជាមួយភោជនីយដ្ឋានឡើងវិញ ជាផ្លូវការ ដើម្បីរៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិ១០ ធ្នូ ឆ្នាំ២០០៩។ ប៉ុន្តែភោជនីយដ្ឋានដែលបានយល់ព្រមថា ទទួលធ្វើម្ហូបអាហារ និងផ្តល់ទីកន្លែងឱ្យបងប្អូនខ្មែរកម្ពុជាក្រោមរៀបចំពិធីនោះ បែរជាបង្អាក់ទៅវិញ ដោយលើកឡើងថា ចំនួនមនុស្ស៥០០ទៅ៦០០នាក់ និងពេលវេលាខ្លីបែបនេះ ភោជនីយដ្ឋានរៀបចំមិនទាន់ទេ។ បញ្ហាស្មុគស្មាញទាំងអស់នេះ គណៈកម្មការរៀបចំទិវាបុណ្យសិទ្ធិមនុស្ស របស់ខ្មែរកម្ពុជាក្រោម មានការលំបាកយ៉ាងខ្លាំង ដោយលិខិតអញ្ជើញភ្ញៀវ និងគណៈអធិបតី ព្រមទាំងនិមន្តព្រះសង្ឃគឺបានចេញអស់ទៅហើយ។ ឥឡូវនៅសល់ពេលតែមួយម៉ោងទៀតប៉ុណ្ណោះ គឺយប់ហើយ ម្ល៉ោះហើយគណៈកម្មការបានសំរេចយកពិធីបុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ២០០៩ ដែលរៀបចំដោយបងប្អូនខ្មែរកម្ពុជាក្រោម ទៅធ្វើនៅផ្ទះ**ឯកឧត្តម យន្ត ថារុ** បិតនៅភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយសង់រោងទាំងយប់ និងរៀបចំទីកន្លែង ម្ហូបអាហារ ព្រមទាំងទូរស័ព្ទទាក់ទងទៅភ្ញៀវយ៉ាងដុតដៃ-ដុតជើង។ លុះព្រឹកឡើងកម្មវិធីបុណ្យនេះ បានប្រព្រឹត្តិទៅតាមកាលកំណត់ ទោះបីជួបឧបសគ្គយ៉ាងណាក៏ដោយ។






គណៈអធិបតី និងភ្ញៀវកិត្តិយស កំពុងស៊ឹងស្មាតគោរពភ្លេងជាតិ និងគោរពវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់ជំនាន់

**អាសយដ្ឋាន: ផ្ទះលេខ១៩ ផ្លូវ២៩៤ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ**

**ទូរស័ព្ទ: ០១១ ៧១ ២៣ ២៥ / ០១១ ៦៣ ៦០ ១២**

**E-mail: kkkwo@yahoo.com**

**ចែកជូនដោយឥតគិតថ្លៃ**

ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិរបស់បងប្អូនខ្មែរកម្ពុជាក្រោម ក៏ដូចជាពិធីផ្សេងៗតែងតែជួបឧបសគ្គគ្រប់ពេលវេលាទាំងអស់ ដូចជាកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩ គឺបងប្អូនខ្មែរកម្ពុជាក្រោមបានរៀបចំបុណ្យរាប់បាត្ររំលឹកខួបលើកទី៦០ ថ្ងៃបារាំងកាត់ទឹកដីខ្មែរឱ្យទៅវៀតណាម។ ពេលនោះក៏មានឧបសគ្គមួយដែរ គឺនៅវេលាម៉ោង១២,០០នាទីយប់ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩ ទើបសាលារាជធានីភ្នំពេញ បានសំរួលផ្តល់កន្លែងឱ្យបងប្អូនខ្មែរកម្ពុជាក្រោមប្រារព្ធពិធីបុណ្យ។ ឥឡូវនេះការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ នៅសល់ពេលតែមួយម៉ោងទៀតយប់ ទើបសាលារាជធានីភ្នំពេញផ្តល់លិខិតឱ្យ។ ដូច្នេះទង្វើទាំងអស់នោះ យើងខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ហើយសូមអំពាវនាវដល់សាលារាជធានីភ្នំពេញ សូមឱ្យមានការយោគយល់ និងអាណិតអាសូរ ព្រមទាំងអនុវត្តច្បាប់ នៃការប្រារព្ធពិធីផ្សេងៗឱ្យបានល្អប្រសើរជាងមុនតទៅទៀត កុំឱ្យមានការយឺតយ៉ាវដូចពេលកន្លងមក។

សមាសភាពគណៈអធិបតី និងភ្ញៀវកិត្តិយសចូលរួមក្នុងពិធីបុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ ដែលរៀបចំឡើងដោយអង្គការ-សមាគមខ្មែរកម្ពុជាក្រោមរួមមាន **ព្រះឧបជ្ឈាយ៍មហា យឿង សិន** ព្រះប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម និងជាព្រះចៅអធិការវត្តសាមគ្គីរង្សី **ព្រះតេជគុណ ច័ន្ទ សុជាត** ព្រះប្រធានសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម **ឯកឧត្តម យន្ត ថារ** ប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម និងជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម ថាច់ សេដ្ឋា** ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ **ឯកឧត្តម ហូរ វ៉ាន់** អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ **ឯកឧត្តម នុត រំដួល** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ **ឯកឧត្តម ឡុង រី** អ្នកតំណាងរាស្ត្រមណ្ឌលក្រចេះ **ឯកឧត្តម ជៀម ច័ន្ទនី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម **ឯកឧត្តម ឃី វណ្ណដេត** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង **ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ** អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាល **លោក សឺន យឿង** នាយកប្រតិបត្តិសមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ **លោកស្រី ព្រំ យ៉ាង** នាយិកាអង្គការស្ត្រីខ្មែរកម្ពុជាក្រោម **លោក ធួន សាវ៉ែន** តំណាងសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម **លោក ប៊ុក កែវ** តំណាងមិត្តសមាគមខ្មែរកម្ពុជាក្រោម **លោក ថាច់ ដួង** អនុប្រធានក្រុមប្រឹក្សាភិបាលអង្គការស្ត្រីខ្មែរកម្ពុជាក្រោម **លោក គឹម ម៉ៅ** តំណាងអង្គការមូលនិធិខ្មែរសំរាប់អ្នកក្រីក្រ ព្រមទាំងតំណាងអាជ្ញាធរដែនដី និងសារពត៌មានជាតិ-អន្តរជាតិដ៏ច្រើនកុះករ ព្រមទាំងបងប្អូនខ្មែរកំណើតកម្ពុជាក្រោមប្រមាណជាង៣០០នាក់ បានចូលរួមធ្វើឱ្យពិធីនោះមានសភាពឱឡារិកអធិកអធម ហួសពីការស្មានទុក ទោះបីមានការផ្លាស់ប្តូរទីកន្លែងយ៉ាងតក់ក្រហល់យ៉ាងណាក៏ដោយ។

បន្ទាប់ពីយុវនារីខ្មែរកម្ពុជាក្រោមបានសូត្របទគោរពភ្លេងជាតិ បទគោរពវិញ្ញាណក្ខន្ធវីរបុរស និងព្រះសង្ឃជយន្តោរួចមក យើងសង្កេតឃើញមាន**ឯកឧត្តម យន្ត ថារ លោក ធួន សាវ៉ែន ឯកឧត្តម ថាច់ សេដ្ឋា លោក សឺន យឿង ឯកឧត្តម ហូរ វ៉ាន់ ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ និងព្រះឧបជ្ឈាយ៍មហា យឿង សិន** មានប្រសាសន៍ និងសង្ឃដីកាជាហូរហែដោយរួមសេចក្តីមកគឺពិភពលោកបាននឹងកំពុងប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិយ៉ាងឱឡារិកអធិកអធម ប៉ុន្តែបងប្អូនខ្មែរកម្ពុជាក្រោមដែលកំពុងរស់នៅក្រោមអាណានិគមរបស់វៀតណាម បាននឹងកំពុងស្រែកហៅឱ្យយើងគេទាំងឡាយ ជួយពួកគាត់ឱ្យមានសិទ្ធិសេរីភាពដូចមនុស្សជាតិទាំងឡាយនៅលើពិភពលោកនេះផង។ ពីព្រោះរាប់ទសវត្សមកហើយ បងប្អូនខ្មែរកម្ពុជាក្រោមពុំដែលស្គាល់ទេ នូវអ្វីដែលហៅថាសិទ្ធិមនុស្សនោះ គឺពីមួយថ្ងៃទៅមួយថ្ងៃ មួយខែទៅមួយខែ មួយឆ្នាំទៅឆ្នាំ ឮនឹងឃើញតែសំដី ព្រមទាំងអំពើអមនុស្សធម៌ពីអាជ្ញាធរវៀតណាម ដែលបានបិទសិទ្ធិសេរីភាពរបស់ពួកគាត់ដូចជា មិនមានសាលារៀនជាភាសាខ្មែរ ការជំនឿព្រះពុទ្ធសាសនា ការគោរពប្រពៃណីទំនៀមទំលាប់របស់ខ្មែរត្រូវបានរឹតបន្តឹង ការរើសអើងប្រកាន់ពូជសាសន៍ ការរឹបអូសយកដីធ្លីនៅតែមានជាបន្តបន្ទាប់។ ម្ល៉ោះហើយក្នុងនាមយើងទាំងអស់គ្នាជាឈាមជ័រខ្មែរ ត្រូវតែគិតគូរ និងមើលឃើញអំពីទុក្ខលំបាករបស់ជនរួមឈាមរបស់យើង ហើយត្រូវជួយរកដំណោះស្រាយជូនពួកគាត់តាមសំណូមពរជាបន្តបន្ទាប់។ ពិសេសការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិរបស់ខ្មែរកម្ពុជាក្រោមត្រូវតែមានជារៀងរាល់ឆ្នាំ។ ពិធីនោះបានបញ្ចប់ប្រកបដោយជោគជ័យ ដោយមានវេរចង្ហាន់ប្រគេនព្រះសង្ឃ និងមានពិសារអាហាររួមគ្នា ជាលក្ខណៈមិត្តភាពក្នុងមហាគ្រួសារខ្មែរ។

# ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

# Khmer Kampuchea Krom Women Organization Bulletin

*ចេញផ្សាយប្រចាំអឌ្ឍមាស ឆ្នាំទី២ លេខ៣៤ ពីថ្ងៃទី១៥-៣១ ខែធ្នូ ឆ្នាំ២០០៩*


## សកម្មភាពរបស់អង្គការ-សមាគមខ្មែរកម្ពុជាក្រោម នៅឆ្នាំ២០០៩

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមយកនូវចំណុចសំខាន់ៗនៃសកម្មភាពប្រចាំឆ្នាំ២០០៩ មកចុះផ្សាយដែលមានខ្លឹមសារដូចតទៅ...

១- នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៩ បានធ្វើសន្និបាតប្រចាំ២០០៨ និងលើកទិសដៅសំរាប់ឆ្នាំ២០០៩ ។

២- នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ គណៈប្រតិភូខ្មែរកម្ពុជាក្រោម បានចូលរួមពិធីបុណ្យសព**សម្តេច ចៅ សែនកុសល**។

៣- នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៩ បានរៀបចំរំលឹកខួប២ឆ្នាំ ថ្ងៃបាតុកម្មអហិង្សារបស់សមណៈនិស្សិត នៅមុខសាលីបុលី ខេត្តឃ្លាំង កម្ពុជាក្រោម។

៤- នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ **ឯកឧត្តម យន្ត ថារ៉ូ** បានចេញសេចក្តីថ្លែងការណ៍ ស្តីពីអាជ្ញាធរខ្មែរ និងវៀតណាមបានហ៊ុំព័ទ្ធផ្ទះលោក ***ស្រី សុធី*** ពាក់ព័ន្ធសៀវភៅពក្យាលរួមមានៈ *១-* សៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាថ្នាក់ទី៣ បោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា *២-*ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម *៣-*សៀវភៅប្រជុំរឿងព្រេងខ្មែរកម្ពុជាក្រោម។

៥- នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ **ឯកឧត្តម យន្ត ថារ៉ូ** បានផ្ញើលិខិតជូនឯកឧត្តម ហោ ណាំហុង តាមរយៈសម្តេច ហេង សំរិន ជំរុញឱ្យស្ថានអគ្គកុងស៊ុលខ្មែរប្រចាំទីក្រុងព្រៃនគរ ជួយយកចិត្តទុកដាក់ និងជួយអន្តរាគមន៍ដល់បងប្អូនខ្មែរកម្ពុជាក្រោម។

៦- នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ បានធ្វើបុណ្យគម្រប់ខួប២ឆ្នាំ ប្រគេនព្រះវិញ្ញាណក្ខន្ធព្រះតេជគុណ អ៊ាង សុខជឿន ដែលសុគតដោយអាថ៌កំបាំង។

៧- នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៩ បានប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិខួបលើកទី៩៩ ដែលមានបងប្អូនខ្មែរកម្ពុជាក្រោមចូលរួម៨៥០នាក់។

៨- នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ បងប្អូនខ្មែរនៅឯដែនដីកម្ពុជាក្រោម បានស្វាគមន៍ការនិមន្ត ទៅដល់របស់**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស** ជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យដារទក្ខិណានុប្បាទាន។

៩- នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានផ្តួចផ្តើមបុណ្យផ្កាស្មារតីសាមគ្គីជាតិ នៅវត្តមហាមន្ត្រី ដើម្បីប្រមូលបច្ច័យយកទៅកសាងចេតិយ នៅខេត្តពោធិសាត់ សំរាប់តំកល់ធាតុបងប្អូនខ្មែរកម្ពុជាក្រោម ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។

១០-នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ គណៈប្រតិភូខ្មែរកម្ពុជាក្រោមបានចូលគាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ដើម្បីថ្វាយព្រះពរ និងថ្វាយពត៌មាន អំពីទុក្ខលំបាករបស់បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោម។

១១-នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៩ បានរៀបចំពិធីដាំដើមពោធិ៍ នៅកន្លែងចេតិយបុព្វបុរសខ្មែរកម្ពុជាក្រោម បិតនៅសហគមន៍បុរីព្រៃនគរ។

១២-នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ បានផ្ញើលិខិតទៅសម្តេច ហេង សំរិន ជួយអន្តរាគមន៍នូវចំណុច៣យ៉ាងគឺ ***១-***ជួយយកចិត្តទុកដាក់ដល់ខ្មែរកម្ពុជាក្រោម ***២-***បញ្ជាក់អត្តសញ្ញាណខ្មែរកម្ពុជាក្រោមឱ្យបានច្បាស់លាស់ ***៣-*** កុំឱ្យមានការចោទប្រកាន់ ពេលនាំយកសៀវភៅអក្សរខ្មែរទៅដែនដីកម្ពុជាក្រោម នៅពេលសម្តេចជួបសវនាការជាមួយថ្នាក់ដឹកនាំវៀតណាម។

១៣-នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ ពិធីអបអរសាទរសមណនិស្សិតខ្មែរកម្ពុជាក្រោម និមន្តទៅបន្តការសិក្សានៅឯបរទេស។

១៤-នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ **ឯកឧត្តម យន្ត ថារ៉ូ** បានចេញសេចក្តីថ្លែងការណ៍ ស្តីពីគាំទ្រចំពោះក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលបានកោះហៅរដ្ឋាភិបាលវៀតណាមទៅបំភ្លឺនៅទីក្រុងហ្សឺណែវស្តីពីបញ្ហារំលោភសិទ្ធិមនុស្ស ពិសេសការរំលោភសិទ្ធិខ្មែរកម្ពុជាក្រោម។

១៥-នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ បានប្រជុំពិភាក្សានៅវត្តសាមគ្គីរង្សី ស្តីពីការត្រៀមរៀបចំពិធីបុណ្យខួបលើកទី៦០។

១៦- នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ គណៈកម្មការបុណ្យបុត្តបង់ទឹកដី បានទទួលព្រះរាជអំណោយពីព្រះវររាជបិតាជាតិខ្មែរ និងព្រះវររាជមាតាជាតិខ្មែរ។

១៧-នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ គណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម បានរៀបចំបុណ្យរាប់បាត្រព្រះសង្ឃ៥០០អង្គ រំលឹកខួបលើកទី៦០ នៅវត្តអង្គតាមិញ ថ្ងៃបារាំងកាត់ទឹកដីកម្ពុជាក្រោមឱ្យទៅវៀតណាម ដោយខុសច្បាប់។

១៨-នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានរៀបចំប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ នៅមុខវត្តបទុមវត្តី ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះអង្គម្ចាស់ក្សត្រីយ៍ព្រះអនុជ នរោត្តម អរុណរស្មី។

១៩-នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៩ ប្រារព្ធពិធីបុណ្យឆ្លងទក្ខិណានុប្បទានប្រគេនព្រះវិញ្ញាក្ខន្ធ ព្រះទេពាចារ្យមហា ត្រឹង យន់ នៅវត្តបទុមវត្តី។

២០-នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** បានផ្ញើលិខិតជូនឯកឧត្តម ហោ ណាំហុង តាមរយៈសម្ដេច ហេង សំរិន សុំឱ្យ កុងស៊ុលខ្មែរទីក្រុងព្រៃនគរ ជួយប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលអាជ្ញាធរវៀតណាមខេត្តឃ្លាំង ធ្វើទុក្ខបុកម្នេញនិងចាប់ខ្លួន។

២១-នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ បានផ្ញើលិខិតទៅប្រធានាធិបតី និងប្រធានរដ្ឋសភាបារាំង សុំកិច្ចព្រមព្រៀងស្ដីពី ការកាត់ទឹកដីកម្ពុជាក្រោម(កូសាំងស៊ីន)ឱ្យទៅវៀតណាមដោយខុសច្បាប់។

២២-នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ ពិភាក្សាការបោះពុម្ពផែនទីកម្ពុជាក្រោម និងស្រង់ស្ថិតិខ្មែរកម្ពុជាក្រោម ដើម្បីចូលគាល់ព្រះមហាក្សត្រ។

២៣-នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** បានស្វាគមន៍ជនភៀសខ្លួនខ្មែរកម្ពុជាក្រោម មកពីប្រទេសថៃ។

២៤-នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩ បងប្អូនខ្មែរកម្ពុជាក្រោមនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រារព្ធពិធីបុណ្យរំលឹកគុណាគ្រូ។

២៥-នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩ ព្រះសង្ឃ១៨អង្គ និងគ្រហស្ថ២នាក់ ត្រូវបានស្ថានទូតវៀតណាមនាំយកទៅថ្ពស្នេហ៍។

២៦-នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** ចេញសេចក្ដីថ្លែងការណ៍ស្វាគមន៍ថ្នាក់ដឹកនាំខ្មែរ ចេះភ្ញាក់រលឹកទៅកាន់ដែនដីកម្ពុជាក្រោម។

២៧-នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** ផ្ញើលិខិតទៅឯកឧត្តម ហោ ណាំហុង តាមរយៈសម្ដេច ហេង សំរិនចាត់ វិធានការដល់កុងស៊ុលខ្មែរនៅទីព្រៃនគរ ឱ្យជួយដោះស្រាយបញ្ហាដីស្រែខ្មែរកម្ពុជាក្រោម ដែលត្រូវវៀតណាមរំលោភយកទាំងកំរោល។

២៨-នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ បានផ្ញើឯកសារទៅថ្នាក់ដឹកនាំវៀតណាម តាមរយៈស្ថានទូតវៀតណាមប្រចាំកម្ពុជា ស្ដីពីការសុំជួយ ដោះស្រាយដល់បងប្អូនខ្មែរកម្ពុជាក្រោម ដែលរងគ្រោះដោយសារការរំលោភយកដីធ្លីពីអាជ្ញាធរវៀតណាម នៅខេត្តមាត់ជ្រូក។

២៩-នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ខ្មែរកម្ពុជាក្រោមអបអរសាទរពិធីបុណ្យសែនដូនតា និងបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ។

៣០-នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** បានលាតត្រដាងទុក្ខលំបាកខ្មែរកម្ពុជាក្រោម នៅក្នុងអង្គប្រជុំរដ្ឋសភាជាតិ។

៣១-នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ បានផ្សព្វផ្សាយនិងចែកចាយផែនទីកម្ពុជាក្រោម ព្រមទាំងប្រតិទិនខ្មែរកម្ពុជាក្រោមឆ្នាំ២០១០។

៣២-នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** ទូលថ្វាយព្រះមហាក្សត្រអំពីទុក្ខលំបាកខ្មែរកម្ពុជាក្រោម នៅក្នុងព្រះបរមរាជវាំង។

៣៣-នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ខ្មែរកម្ពុជាក្រោម ប្រារព្ធខួបលើកទី៣៣ ទិវាចលនាតស៊ូទាមទារសិទ្ធិសេរីភាពនៅដែនដីកម្ពុជាក្រោម។

៣៤-នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** បានលើកឡើងអំពីទុក្ខលំបាកខ្មែរកម្ពុជាក្រោមជូនអង្គប្រជុំ នៅប្រទេសហ្វីលីពីន។

៣៥- នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រជុំជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អំពីការរំលោភសិទ្ធិមនុស្សមកលើខ្មែរកម្ពុជាក្រោម។

៣៦- នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ អបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ មានបងប្អូនខ្មែរកម្ពុជាក្រោមចូលរួមប្រមាណ៣០០នាក់។

៣៧- នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ **ឯកឧត្តម យុន្ត ថារ៉ូ** បានផ្ញើលិខិតទៅឯកឧត្តម ហោ ណាំហុង តាមរយៈសម្ដេច ហេង សំរិន ចាត់ វិធានការទៅកុងស៊ុលខ្មែរនៅទីក្រុងព្រៃនគរ ដើម្បីអន្តរាគមន៍ដល់ខ្មែរកម្ពុជាក្រោម នៅខេត្តមាត់ជ្រូក ដែលត្រូវវៀតណាមវាយដំ និងរំលោភយកដីស្រែ។

៣៨- នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ បានធ្វើសន្និបាតប្រចាំ២០០៩ និងលើកទិសដៅសំរាប់ឆ្នាំ២០១០។